**ជំងឺឬវិការៈផ្លូវចិត្ត** (mental disease)

យុត្តិសាស្ត្រអន្តរជាតិ ក៏ដូចជាលក្ខន្តិកៈនៃ ICC ទទួលស្គាល់ជំងឺផ្លូវចិត្ត ជាការដោះសារ (excuse) រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ វាត្រូវតែធ្ងន់ធ្ងរ អសមត្ថភាពទាំងស្រុង ក្នុងការវាយតម្លៃពីផលវិបាកនៃទង្វើរបស់ខ្លួន។ ច្បាប់ក្នុងស្រុកប្រើពាក្យ "វិបល្លាសស្មារតី" (Insanity)។

នេះខុសនឹងវិការៈផ្លូវចិត្តមិនទាំងស្រុង (partial mental defect) ដែលអាចត្រឹមតែទទួលបាននូវការបន្ថយទោស (mitigating circumstance)។ នៅក្នុងប្រទេសកំមុនឡូ ជំនួសឲ្យការចោទពីបទមនុស្សឃាតចេតនា (murder) តុលាការ អាចចោទបទល្មើសស្រាលជាង (manslaughter)។

ជនត្រូវចោទ ដែលអះអាងថាមានវិការៈផ្លូវចិត្ត មានបន្ទុកបង្ហាញភស្តុតាងគាំទ្រ ក្នុងកម្រិតភស្តុតាងលើសពី៥០ភាគរយ (balance of probability) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 415-416)។

**ខ្លឹមសារបន្ថែម៖** ក្រមព្រហ្មទណ្ឌកម្ពុជា ប្រើពាក្យ "វិបល្លាសស្មារតី" ក្នុងមាត្រា៣១។ ពាក់ព័ន្ធជាមួយនឹងបញ្ហានេះ មានការសន្មតថា អ្នកប្រព្រឹត្តបទល្មើសមានស្មារតីល្អ (not insane) អាស្រ័យហេតុនេះ គាត់មានបន្ទុកភស្តុតាង (burden of proof) ថាគាត់មានវិការៈផ្លូវចិត្ត។ ការទាមទារដូចនេះ មិនផ្ទុយនឹងគោលការណ៍សន្មតថាមិនមានទោស (presumption of innocence) ទេ ដោយសារគាត់មិនមែនបង្ហាញធាតុផ្សំបទល្មើស ដែលជាបន្ទុករបស់រដ្ឋអាជ្ញា (prosecution) ឡើយ។